ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តឲ្ចត្តរមានជ័យ

លេខ: ៣៤៥ សជណ/ឧជ

ឧត្តរមានជ័យថ្ងៃទី...៣៤...ខែកញ្ញាឆ្នាំ២០១៥

សេចក្តីជូនដំណឹង

ស្តីពី

ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៦

សាលាខេត្តឲ្ចត្តរមានជ័យ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៦ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ ។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

អ្នកទទួលការត្រូវបានបែងចែកជា *០៣* ប្រភេទ ៖

ប្រភេទទី ១: អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង...។ល។)

ប្រភេទទី ២: អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រាលគ្រួសក្រហម.....។ល។)

ប្រភេទទី ៣: អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញពិសេស សម្រាប់ ការងារពិសេសដូចជា អណ្តូងស្នប់...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស សម្ភារ: និងបរិក្ខារគ្រប់គ្រាន់ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើ និងត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិចចំនួន០២ ក្នុងអំឡុងពេល០៥ ឆ្នាំចុងក្រោយ ។ អនុគណ:កម្មការបុរេលក្ខណសម្បត្តិ និងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេស ដោយផ្អែកលើលក្ខណវិនិច្ឆ័យដូចបានបរិយាយក្នុងពាក្យស្នើសុំចុះបញ្ជីព្រមទាំងពិនិត្យគុណភាពការងារ ភាពស្មោះត្រង់ការអនុវត្តការងារ ទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណ:កម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូន **អភិបាលខេត្ត** ដើម្បីពិនិត្យនិងសម្រេច ។

អាស្រ័យហតុនេះ បើអ្នកទទួលការណាមានបំណងចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យនៅ **ទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត** ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី *១៦ខែតុលា* ឆ្នាំ*២០១៥* វេលាម៉ោង *០៤.៣០* ល្ងាច ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យជាថ្មីឡើងវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះនៅទីចាត់ការផែនការ និងវិនិយោគសាលាខេត្តដោយឥតគិតថ្លៃរៀងរាល់ម៉ោងធ្វើការ ឬអាចទាញយកពីគេហទំព័ររបស់គណ:កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបត្រយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។

អាស្រ័យហេតុនេះ សូមសាធារណជន និងអ្នកទទួលការទាំងអស់មេត្តាជ្រាបជាព័ត៌មាន ។

អភិបាលខេត្ត

ស-ថាវី

ចម្លងជូន

- *លេខាធិការដ្ឋាន គ.ជ.អ.ប (ដើម្បីគោរពជូនជ្រាប)*
- *ឯកសារ-កាលាប្បវត្តិ*